មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មានរបស់ ម.ស.ម.ក
# អាជ្ញាធរខេត្តកោះកុងហាមឃាត់ក្រុមសកម្មជនជិះកង់ដើម្បីបរិស្ថាន ក្នុងយុទ្ធនាការជិះកង់ដើម្បីសង្គ្រោះកោះកុងក្រៅ

**កាលបរិច្ឆេទនៃហេតុការណ៍៖** ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០
**ប្រភេទអ្នកការពារសិទ្ធិមនុស្ស៖** សកម្មជនបរិស្ថាន
**ទីកន្លែង៖** ខេត្តកោះកុង
**ប្រភេទនៃការគំរាមកំហែង ៖** សេរីភាពជួបប្រជុំ

នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ ក្រុមយុវជនបរិស្ថានចំនួន ១៨នាក់ត្រូវបានអាជ្ញាធរស្រុកកោះកុងរារាំងការជិះកង់ពីខេត្តកោះកុងទៅកាន់រាជធានីភ្នំពេញ។ យុទ្ធនាការសកម្មជនទាំងនោះគឺចូលរួម "សង្គ្រោះកោះកុងក្រៅ" ជាទីដែលពួកគេមានបំណងជិះកង់ឆ្ពោះទៅកាន់រាជធានីភ្នំពេញដើម្បីដាក់ញ្ញត្តិទៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ពួកគេមានបំណងស្នើសុំឱ្យរដ្ឋាភិបាលដាក់បញ្ចូលកោះកុងក្រៅជាតំបន់ការពារឧទ្យានជាតិសមុទ្រដើម្បីអភិរក្សធនធានធម្មជាតិនៅកោះនោះ។

នៅពេលដែលចាប់ផ្តើមយុទ្ធនាការនោះ អាជ្ញាធរតម្រូវវាស់ស្ទង់កម្តៅសកម្មជនជាមុនសិន។ សកម្មជនទាំងនោះបានបដិសេធនៅពេលដែលអាជ្ញាធរស្នើសុំឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណ ប៉ុន្តែពួកគេយល់ព្រមសរសេរឈ្មោះរបស់ពួកគេឱ្យទៅអាជ្ញាធរជំនួសវិញ។ អាជ្ញាធរក៏ទាមទារចង់ពិនិត្យញត្តិ ហើយបានឱ្យក្រុមសកម្មជនទាំងនោះផ្តិតមេដៃក្នុងលិខិតមួយដើម្បីបញ្ជាក់ថាពួកគេមិនដាក់ញត្តិទៅអាជ្ញាធរមូលដ្ឋាននោះទេ ក៏ប៉ុន្តែក្រុមសកម្មជនបានបដិសេធសំណើរទាំងពីរនោះ។ ប្រហែលម៉ោង ១១:៣០ នាទីព្រឹក នគរបាលស្រុកកោះកុងបានរឹបអូសកង់ចំនួន១០ របស់ក្រុមយុវជន។ នៅម៉ោងប្រហែល ២:០០ រសៀល នគរបាលស្រុកកោះកុងបានអញ្ជើញសកម្មជនទាំងអស់ពិភាក្សាគ្នាពាក់ព័ន្ធនឹងការរឹបអូសយកកង់របស់ពួកគេ ដោយស្នើជួបសកម្មជនម្នាក់ម្តងៗ ប៉ុន្តែសកម្មជនទាំងនោះបានបដិសេធចំពោះសំណើនេះ ព្រោះពួកគេបានប្រាប់ពីគោលបំណងនៃយុទ្ធនាការដល់អាជ្ញាធររួចទៅហើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ( ០ ) ៨៨ ៨១ ៤២ ៧៨៣ ឬអ៊ីម៉ែល ៖ yuthyia@cchrcambodia.org។